# Medi-Cal Managed Care មានការផ្លាស់ប្តូរក្នុងខែមករា ឆ្នាំ 2023 សម្រាប់អ្នកទទួលអត្ថប្រយោជន៍ (Medi-Medi) ដែលមានលក្ខណៈសម្បត្តិទទួលទាំងពីរ




+




នៅថ្ងៃទី 1 ខែមករា ឆ្នាំ 2023 ការធានារ៉ាប់រងសុខភាពរបស់ Medi-Cal នៅតាមបណ្តាខោនធីមួយចំនួន នឹងផ្លាស់ប្តូរពី Fee-For-Service (FFS) Medi-Cal ទៅជា Medi-Cal Managed Care វិញ។ សេចក្តីជូនដំណឹងនឹងត្រូវបានផ្ញើជូនត្រឹមថ្ងៃទី 1 ខែវិច្ឆិកា និងថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2022។ **អត្ថប្រយោជន៍ និងអ្នកផ្តល់សេវាក្នុងគម្រោង Medicare របស់អ្នកនឹងមិនមានការផ្លាស់ប្តូរទេ។**

សម្រាប់អ្នកដែលមានទាំងគម្រោង Medicare និង Medi-Cal នោះការធានារ៉ាប់រងរបស់ Medi-Cal នឹងមានការផ្លាស់ប្តូរទៅជាការថែទាំក្រោមការគ្រប់គ្រងរបស់គម្រោង Medi-Cal វិញ នៅក្នុងខោនធីដែលបានចុះក្នុងបញ្ជីខាងក្រោមនេះ។ នៅក្នុងខោនធីទាំងអស់ផ្សេងទៀត Medi-Cal ត្រូវបានផ្តល់ជូនតាមរយៈគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់ Medi-Cal រួចទៅហើយ៖

> ខោនធីទាំងនោះរួមមាន ៖ Alameda, Alpine, Amador, Butte, Calaveras, Colusa, Contra Costa, El Dorado, Fresno, Glenn, Imperial, Inyo, Kern, Kings, Madera, Mariposa, Mono, Nevada, Placer, Plumas, Sacramento, San Benito, San Francisco, San Joaquin, Sierra, Stanislaus, Sutter, Tehama, Tuolumne, Tulare, និង Yuba ។

## ការចូលរួមជាមួយនឹងគម្រោង Medi-Cal Managed Care មួយនឹងមិនផ្លាស់ប្តូរអត្ថប្រយោជន៍ Medicare របស់អ្នកទេ

អត្ថប្រយោជន៍ Medicare របស់អ្នកនឹងមិនផ្លាស់ប្តូរទេ បន្ទាប់ពីអ្នកចូលរួមក្នុងគម្រោង Medi-Cal មួយ។ ការចូលរួមក្នុងគម្រោង Medi-Cal នឹងមិនប៉ះពាល់ដល់អ្នកផ្តល់សេវា Medicare របស់អ្នក ឬជម្រើសនៃគម្រោង Medicare Advantage ឬ Medicare ដើមរបស់អ្នកទេ។ អ្នកផ្តល់សេវាក្នុងគម្រោង Medicare មិនចាំបាច់ត្រូវតែមកពីបណ្តាញនៃគម្រោង Medi-Cal ដើម្បីបន្តផ្តល់ការថែទាំដល់អ្នកទេ។ អ្នកនៅតែអាចជួបអ្នកផ្តល់សេវានៃគម្រោង Medicare របស់អ្នក ហើយទៅកាន់មន្ទីរពេទ្យដែលអ្នកជួបនឹងគ្រូពេទ្យនៃគម្រោង Medicare របស់អ្នកបានដដែល។

## ការជ្រើសរើសគម្រោង Medi-Cal Managed Care

ជម្រើសនៃគម្រោង Medi-Cal របស់អ្នកអាស្រ័យលើខោនធីដែលអ្នករស់នៅ និងថាតើអ្នកស្ថិតនៅក្នុងគម្រោង Medicare Advantage ដែរឬទេ។ សូមស្វែងយល់បន្ថែមអំពីជម្រើសរបស់អ្នកដោយចូលទៅកាន់ Health Care Options (HCO) ឬទូរសព្ទទៅលេខ 1-800-430-5005។

## តើគម្រោង Medi-Cal Managed Care គឺជាអ្វី?

គម្រោង Medi-Cal គឺជាគម្រោងសុខភាព ដែលសម្របសម្រួលដល់ គ្រប់អត្ថប្រយោជន៍ Medi-Cal របស់អ្នកទាំងអស់។ គម្រោង Medi-Cal របស់អ្នកអាចផ្តល់ឱ្យអត្ថប្រយោជន៍បន្ថែមទៀតទៅដល់អ្នក រួមជាមួយនឹងអត្ថប្រយោជន៍ Medicare របស់អ្នក។ អត្ថប្រយោជន៍ Medi-Cal ទាំងនេះរួមមាន៖

- ការសម្របសម្រួលអំពី សេវា និងជំនួយរយៈពេលវែង (Long-Term Services and Supports) ណាមួយដែលអ្នកប្រើប្រាស់ ឬត្រូវការ
- មធ្យោបាយធ្វើដំណើរទៅ និងមកពីការណាត់ជួបដែលទាក់ទងនឹងផ្នែកព្យាបាល
- សម្ភារបរិក្ខារ និងគ្រឿងផ្គត់ផ្គង់ពេទ្យពិសេសដើម្បីជួយទៅដល់អ្នកក្នុងការគ្រប់គ្រងសុខភាពរបស់អ្នក
- ការពង្រឹងលើការគ្រប់គ្រងការថែទាំសុខភាព (Enhanced Care Management) និងជំនួយសហគមន៍ (Community Supports) ដើម្បីជួយទៅដល់អ្នកក្នុងការបន្តមានឱ្យសុវត្ថិភាពក្នុងផ្ទះរបស់អ្នក

បន្ទាប់ពីចូលរួមជាមួយគម្រោង Medi-Cal ហើយ អ្នកនៅតែអាចទទួលបានសេវានៃគម្រោង Medi-Cal មួយចំនួនតាមរយៈភ្នាក់ងារផ្សេងទៀត រួមមាន៖

- In-Home Supportive Services (IHSS)
- សេវាឯកទេសសុខភាពផ្លូវចិត្ត និងព្យាបាលបញ្ហាប្រើសារធាតុញៀន
- សេវាសុខភាពធ្មេញរបស់ Medi-Cal
- សេវាមជ្ឈមណ្ឌលក្នុងតំបន់
- សេវាឱសថស្ថាន Medi-Cal ភាគច្រើន

## ការចូលរួមក្នុងគម្រោង Medi-Cal Managed Care នឹងមិនផ្លាស់ប្តូរ IHSS របស់អ្នក ឬជំនួយផ្សេងទៀតនោះទេ

អត្ថប្រយោជន៍ Medi-Cal ខាងក្រោមនឹងមិនផ្លាស់ប្តូរទេ នៅពេលអ្នកចូលរួមក្នុងគម្រោង Medi-Cal៖

- In-Home Supportive Services (IHSS)
- Community-Based Adult Services (CBAS)
- Multipurpose Senior Services Program (MSSP)
- សេវាមណ្ឌលថែទាំសុខភាព

## ប្រភពព័ត៌មានបន្ថែម

- សម្រាប់ព័ត៌មានបន្ថែមអំពីជម្រើសគម្រោង Medi-Cal ក្នុងខោនធីរបស់អ្នក សូមមើលគេហទំព័រ Health Care Options ឬទូរសព្ទទៅលេខ 1-800-430-5005
- សម្រាប់ការប្រឹក្សាដោយឥតគិតថ្លៃអំពីជម្រើស Medicare សូមទាក់ទងទៅកាន់កម្មវិធី Health Insurance Counseling and Advocacy Program (HICAP)៖ 1-800-434-0222
- ប្រសិនបើអ្នកត្រូវការជំនួយជាមួយបញ្ហា ដែលគម្រោងសុខភាពរបស់អ្នកមិនអាចដោះស្រាយបាន សូមទូរសព្ទទៅកាន់ Medicare Medi-Cal Ombudsman៖ 1-855-501-3077
- សម្រាប់ព័ត៌មានបន្ថែមអំពីការផ្លាស់ប្តូរការថែទាំក្រោមការគ្រប់គ្រងរបស់ Medi-Cal សូមមើលនៅគេហទំព័រនេះត្រង់ផ្នែក California Department of Health Care Services៖ Statewide Medi-Cal Managed Care Enrollment for Dual Eligible Beneficiaries